# អភិវឌ្ឍជំនាញក្នុងការអាន

ការដឹងរបៀបអានប្រកបដោយប្រសិទ្ធភាពគឺជាជំនាញសំខាន់មួយ ជាជំនាញដែលគ្រប់សិស្សនិស្សិតថ្នាក់មហាវិទ្យាល័យគួរតែខំរៀនឲ្យបានស្ទាត់ជំនាញខ្លាំង។ ក្នុងពេលអាន គោលបំណងរបស់អ្នកមិនត្រឹមតែចង់យល់អត្ថន័យរបស់ពាក្យនិមួយៗនៅលើទំព័រទាំងនោះទេ គឺថែមទាំងចង់ដឹងថាតើពាក្យទាំងនោះចង្អុលប្រាប់ឲ្យយើងដឹងអំពីអ្វីទៀត។ បើអ្នកអានសៀវភៅមួយក្បាល ឬអត្ថបទមួយដែលប្រកាន់ទស្សនៈលើប្រធានបទឬសាច់រឿងមួយ អ្នកត្រូវតែវាយតម្លៃភាពគួរឲ្យទុកចិត្តរបស់អ្នកនិពន្ធនិងវាយតម្លៃភាពសមរម្យនៃគំនិតរបស់គាត់ផងដែរ។ ប្រឈមមុខទល់នឹងករណីរបៀបនេះ អ្នកចាំបាច់ត្រូវតែបើកចំហទទួលយកគំនិតថ្មីនិងមានឆន្ទៈចង់សួរដេញដោលលើអ្វីដែលអ្នកបានអាននិងពីរបៀបដែលអ្នកមានប្រតិកម្មតប។

### ការពិនិត្យមើលត្រួសៗជាមុន

ជាលើតំបូងដែលអ្នកចាប់កាន់សៀវភៅមួយក្បាលឬអត្ថបទមួយ ចូរពិនិត្យមើលនិងអានត្រួសៗ មានន័យថាអ្នកចាំបាច់ត្រូវតែអានត្រួសៗដើម្បីចាប់យកគោលគំនិតនៃប្រធានបទនិងការផ្ដោតចំណាប់អារម្មណ៍របស់អ្នកនិពន្ធជាមុនសិន។ ពេលអ្នកអានសៀវភៅមួយក្បាលត្រួសៗ គឺអ្នកពិនិត្យមើលមាតិការរឿងព្រមទាំងលិបិក្រម(Index: ពាក្យសំខាន់ៗដែលគេស្រង់យកទៅបោះពុម្ពនៅផ្នែកចុងក្រោយរបស់សៀវភៅ)។ ការចំណាយពេលមួយភ្លែតដើម្បីពិនិត្យមើលមាតិការរឿងនិងលិបិក្រមពិតជាមានប្រយោជន៍ជួយឲ្យអ្នករកឃើញថាតើសៀវភៅនោះចង់និយាយអំពីប្រធានបទអ្វី ហើយការនេះវាមានសារៈសំខាន់សម្រាប់អ្នកខ្លាំងណាស់។ ក្នុងពេលអ្នកបើកសៀវភៅអានពីជំពូកមួយទៅជំពូកមួយ ចូរក្រឡេកមើលរូបភាព ក្រាហ្វិក និងតារាង ហើយចូរអានឃ្លាពន្យល់នៅខាងក្រោមរូបភាព ក្រាហ្វិកនិងតារាងទាំងនោះ។ ពេលអ្នកអានត្រួសៗអត្ថបទមួយ ចូរក្រឡេកមើលក្បាលសាច់រឿងសំខាន់ៗ ឬអត្ថបទនៅក្នុងប្រអប់។ រួចហើយចូរអានត្រួសៗវាក្យខ័ណ្ឌសេចក្ដីផ្ដើមនិងវាក្យខ័ណ្ឌសេចក្ដីសន្និដ្ឋានដើម្បីសង្ខេបយកគោលចំណុចរបស់អ្នកនិពន្ធ។ ការប្រកាសប្រធានបទ ឃ្លាសំខាន់បង្ហាញគោលគំនិត ពាក្យគន្លឹះសំខាន់ៗលេចឡើងច្រំដែល ព្រមទាំងពាក្យឬប្រយោគភ្ជាប់ឃ្លាឬវាក្យខ័ណ្ឌក៏មានសារៈសំខាន់ក្នុងការរកឲ្យឃើញចំណុចដែលអ្នកនិពន្ធចង់លើកមកនិយាយដែរ។

### គូសសញ្ញាសំគាល់

ពេលដែលអ្នកបានបញ្ចប់ការអានត្រួសៗលើអត្ថបទមួយឬសៀវភៅមួយក្បាល ចូរបន្តគូសចំណាំពាក្យគន្លឹះសំខាន់ៗរបស់អ្នកនិពន្ធនិងទំនាក់ទំនងរវាងពាក្យគន្លឹះទាំងនោះ។ ក្នុងពេលអ្នកគូសសញ្ញាសំគាល់ ចូរប្រើនិម្មិតសញ្ញា ឬគូសបន្ទាត់ពីក្រោមដើម្បីសំគាល់គំនិតសំខាន់ៗ។ បើអ្នកខ្ចីសៀវភៅពីបណ្ណាល័យ ចូរថតចំលងឯកសារនោះរួចគូសចំណាំលើច្បាប់ចំឡងនោះ។ សូមចងចាំថា អ្នកត្រូវប្រើតែនិម្មិតសញ្ញាណាដែលអ្នកពិតជាអាចចាំបានថាវាមានន័យយ៉ាងណាពេលអ្នកចាប់អានអត្ថបទឬសៀវភៅនោះពេលក្រោយទៀត។

### បញ្ជីពិនិត្យ៖ និម្មិតសញ្ញាសំគាល់មួយចំនួន

- គំនូសបន្ទាត់ពីក្រោមពាក្យឬឃ្លាមានន័យថាជាពត៌មានដែលអ្នកនឹងត្រលប់មកអានម្ដងទៀត។
- គូសប្រអប់ឬរង្វង់មូលលើពាក្យឬឃ្លាសំខាន់ៗ។
- ដាក់សញ្ញាសួរក្បែរឃ្លាឬពាក្យណាច្របូកច្របល់ ចំណុចមិនច្បាស់ ពាក្យដែលអ្នកត្រូវតែស្វែងរកន័យពីវចនានុក្រម។
- គូសបន្ទាត់ភ្ជាប់ឬព្រួញដើម្បីបង្ហាញពីទំនាក់ទំនងរវាងគំនិត។
- ចុះលេខលើចំណុចដែលលេចឡើងជាលំដាប់លំដោយ។
- គូសបន្ទាត់បញ្ឈរនៅក្បែរវាក្យខ័ណ្ឌឬវគ្គក្នុងជាយក្រដាសសម្រាប់បង្ហាញចំណុចសំខាន់ៗ។
- គូសផ្កាយត្រង់ចំណុចសំខាន់មែនទែន។